# ព្រែកទាល់

**A1, A4i & A4iii**



**ខេត្ត** : បាត់ដំបង

**ស្រុក** : ឯកភ្នំ សង្កែ និង មោងឫស្សី

**ផ្ទៃដី ( ហិកតា)** : ៣៩.៨៧៣

**រយៈកំពស់ ( ម៉ែត្រ)** : ៤ ដល់ ៧

**កូអរដោនេចំណុចកណ្តាល** : ១៣$^{0}$០៧´ជ ១០៣$^{0}$ ៣៩´ក

## ការពិពណ៌នាទីកន្លែង

តំបន់ព្រែកទាល់ គឺជាតំបន់មួយក្នុងចំណោមតំបន់ទាំងឡាយដែលមានព្រៃលិចទឹកនៅគង់វង្សបានល្អបំផុតនៅជុំវិញបឹងទន្លេសាប ។ ប្រព័ន្ធអេកូឡូស៊ីនេះអាចសម្រប និង ធន់បានជាមួយនឹងភាពខុសៗគ្នានៃកំរិតកំពស់ទឹកតាមរដូវកាល ដែលមានជំរៅរហូតដល់ទៅ១០ម៉ែត្រ និង មានព្រៃលិចទឹកល្វឹងល្វើយដែលមានកំពស់ពី ៧ ដល់ ១៥ម៉ែត្រ គ្របដណ្តប់លើសលប់ដោយប្រភេទរាំងទឹក (Barringtonia acutangula ) និង ផ្តល់ ឬ អាចម៍កណ្តុរ (Diospyros cambodiana) ហើយភាពផ្សេងៗនៃប្រភេទដើមឈើវល្លិ និង ព្រៃគុម្ពោតទាបៗ ។ នៅក្នុងរដូវប្រាំង (ពីខែមករា-ឧសភា) ដើមឈើធំៗទាំងនេះបានទ្រទ្រង់នូវបន្ទាយពងកូនធំបំផុតរបស់ពពួករនាល ទុង និង ត្រយ៉ងនៅក្នុងតំបន់អាស៊ីអគ្នេយ៍ ។ តំបន់ត្វស្លាបសំខាន់ៗ (IBA) នេះស្ថិតចំកណ្តាលតំបន់ស្នូលព្រែកទាល់នៃតំបន់បំរុងជីវមណ្ឌលបឹងទន្លេសាប ហើយរួមបញ្ចូលបន្ទាយពងកូនសត្វស្លាបទឹកទាំងអស់ និង តំបន់ព្រៃលិចទឹងវាលភក់សំខាន់ៗផ្សេងទៀត ។ តំបន់នេះទាំងមូលស្ថិតនៅក្នុងឡូតិ៍នេសាទលេខ២នៃខេត្តបាត់ដំបងដែលគេធ្វើការនេសាទត្រីមានទ្រង់ទ្រាយជាលក្ខណៈពាណិជ្ជកម្មចាប់ពីខែមករារហូតដល់ខែកក្កដា ហើយការចូលទៅកាន់តំបន់នេះមានការពិបាកចំពោះអ្នកណាដែលមិនមែនជាបុគ្គលិកផ្ទាល់របស់ឡូតិ៍នេសាទ ។ បន្ទាយពងកូនសត្វស្លាបទឹកព្រែកទាល់ ប្រភេទសត្វខ្លះមានចំនួនច្រើនបំផុតក្នុងពិភពលោកដូចជា ទុងប្រផេះ ត្រដក់ធំ ហើយប្រហែលអាចជាកន្លែងតែមួយគត់ក្នុងពិភពលោក ដែលមានរនាលសពងកូននៅក្នុងតំបន់ទឹកសាប ។ ជាងនេះទៀត តំបន់នេះបានទ្រទ្រង់បន្ទាយពងកូននៅរដូវវស្សារបស់ស្មោញ អកត្រី ក្បាលប្រផេះ និងប្រភេទពពួលទឹក ដែលគេបានកត់ត្រាកូនរបស់វាពីតំបន់នេះ ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| កុកគ្រោងធំ | Great Egret | *Casmerodius albus* | | A4i |
| ក្អែកទឹកតូច | Indian Cormorant | *Phalacrocorax fuscicollis* | | *A4i* |
| ក្អែកទឹកមធ្យម | Indian Cormorant | *Phalacrocorax fuscicollis* | | A4i |
| ចង្កៀលខ្យង | Asian Openbill | *Anastomus oscitans* | | A4i |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 | A4i |
| ត្រដក់ធំ | Greater Adjutant | *Leptoptilos dubius* | A1 | A4i |
| ត្រយ៉ងខ្លួន ស | Black-headed Ibis | *Threskiornis melanocephalus* | A1 | A4i |

| | | | | |
|---|---|---|---|---|
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 | A4i |
| ពពូលទឹក | Masked Finfoot | *Heliopais personata* | A1 | |
| រនាលពណ៌ | Painted Stork | *Mycteria leucocephala* | A1 | A4i |
| រនាល ស | Milky Stork | *Mycteria cinerea* | A1 | A4i |
| ស្មោញ | Darter | *Anhinga melanogaster* | A1 | A4i |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 | |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

រញ្ជីប្រផេះ ស្វាក្តាម និង ស្វាព្រាម ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

ក្រពើទន្លេ (ក្រពើត្រី) អណ្តើកបិទមុខស្នូកខ្មៅ អណ្តើកក្របីក្បាលលឿង អណ្តើកសកល និង កន្ធាយអាស៊ី ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ការប្រមូលយកពងកូនពីសំបុកនៅតែជាការគំរាមកំហែងខ្លាំងបំផុតចំពោះការរស់រានមានជីវិតរបស់សត្វស្លាបទឹក នៅក្នុងបន្ទាយពងកូនបឹងទន្លេសាប ។ ក្រុមអ្នកប្រមូលយកពងកូនសត្វស្លាបទឹកធំៗមានបំណងទៅកាន់បន្ទាយពងកូនរបស់ស្មោញ ទុង រនាល និង ត្រយ៉ង ដើម្បីប្រមូលពងកូន ហើយបានធ្វើដំណើរជាច្រើនដងចូលទៅក្នុងព្រៃលិចទឹកក្នុងអំឡុងពេលរដូវពងកូន ។ ការធ្វើអន្តរាគមន៍របស់មន្ត្រីជំនាញ និង ក្រុមអភិរក្សអន្តរជាតិ ហើយនឹងការបង្កើតឡើងទីស្នាក់ការបរិស្ថានព្រែកទាល់បានកែលំអស្ថានភាពនៅក្នុងបន្ទាយពងកូនយ៉ាងសំខាន់នោះ ចាប់តាំងពីឆ្នាំ១៩៩៧ ។ ការប្រមូលយកពងកូនធ្វើឡើងដោយប្រជាជនរស់នៅក្នុងបឹងទន្លេសាប (អ្នកនេសាទ) បានថយចុះគួរយ៉ាងច្រើន ប៉ុន្តែគេរាយការណ៍ថា សកម្មភាពនេះនៅតែមានធ្វើឡើងដោយប្រជាកសិករដែលធ្វើដំណើរទៅកាន់បឹងទន្លេសាបពីបណ្តាតំបន់ខាងលើៗក្នុងខេត្តបាត់ដំបង ។

ក្រៅពីការនេសាទ ប្រាក់ចំណូលសំខាន់បានមកពីការលក់អុសនៃព្រៃលិចទឹក ។ ការកាប់អុសសម្រាប់ការប្រើប្រាស់ក្នុងការដាំស្លក្នុងមូលដ្ឋានត្រូវបានគេជឿថា មាននិរន្តរភាពនៅពេលដែលរុក្ខជាតិព្រៃលិចទឹកដុះលូតលាស់ឡើងវិញយ៉ាងឆាប់រហ័សគួរឱ្យកត់សំគាល់បន្ទាប់ពីមានការកាប់ហើយ ។ ទោះជាយ៉ាងណាក៏ដោយ ការកាប់ដើមឈើធំៗអាចប៉ះពាល់ធ្ងន់ធ្ងរដល់ដើមឈើដែលសត្វស្លាបទឹកធំៗធ្វើសំបុកពងកូន ។

**អនុសាសន៍**

ការផ្តួចផ្តើមការអភិរក្សនាពេលថ្មីៗធ្វើឡើងជាមួយក្រុមអភិរក្សតាមមូលដ្ឋានការពារបន្ទាយសត្វស្លាប គួរតែធ្វើការផ្គត់ផ្គង់បន្តទៀត និង ពង្រីកតាមរយៈការជ្រើសរើសអ្នកភូមិបន្ថែម និង ការផ្តល់វគ្គបណ្តុះបណ្តាល និង ធនធានទាំងឡាយដល់ពួកគាត់ ។

តំបន់ស្នូលព្រែកទាល់ គួរតែកាត់ចេញពីប្រព័ន្ធឡូតិ៍នេសាទ ហើយបង្កើតការអភិរក្សជាដែលបំរុងទីជំរកមច្ឆាជាតិស្ថិតនៅក្រោមច្បាប់ជលផល ។

មន្ត្រីជំនាញគួរតែធ្វើការជាមួយក្រុមអភិរក្សមូលដ្ឋាន ដើម្បីត្រួតពិនិត្យការប្រមាញ់ និង សកម្មភាពនេសាទខុសច្បាប់នៅក្នុងតំបន់ស្នូលព្រែកទាល់ដោយអនុវត្តច្បាប់ជលផល និង ច្បាប់ព្រៃឈើ ។

ធ្វើការជាមួយក្រុមអភិរក្សមូលដ្ឋាន ដើម្បីបង្កើតឡើងនូវច្បាប់ និង រចនាសម្ព័ន្ធសម្រាប់ផ្នែកទេសចរណ៍ធម្មជាតិ ជាពិសេស ផ្តោតលើការកាត់បន្ថយនូវការរំខានដល់បន្ទាយពងកូនរបស់សត្វស្លាប និង ចែកចាយដំណើរការដោយសមធម៌ជាមួយនឹងសហគមន៍មូលដ្ឋាន ។

ការផ្តួចផ្តើមគំនិតការអប់រំបរិស្ថាននាពេលថ្មីៗ ធ្វើជាមួយទាំងមនុស្សពេញវ័យ និង ក្មេងតូចៗ ជាពិសេសនៅសាលារៀនគួរតែផ្តត់ផ្គង់បន្តទៀត និង ពង្រីកឱ្យបានទូលំទូលាយនៅតាមសហគមន៍ក្នុងតំបន់ទាំងមូល ។

ការសិក្សាស្រាវជ្រាវបន្តគួរតែផ្តើមឡើង ដើម្បីកំណត់រកតំបន់រកស៊ីសំខាន់ៗរបស់សត្វស្លាបទឹកក្នុងអំឡុងពេលរដូវពងកូន និង បង្កើតឡើងកម្មវិធីរយៈពេលយូរសម្រាប់ពិនិត្យឃ្លាំមើលចំនួនសត្វស្លាប ។

### ឯកសារយោង


Carr, P. (1998) Notes on the trade of large waterbirds for food in Cambodia. *Bull. Oriental Bird Club* 27: 49-50.

Ear-Dupuy, E., Briggs, E., Hong Chamnan and Keo Omaliss (1998) *Waterbird conservation in Prek Toal area, Battambang province, Cambodia*. Phnom Penh: Wetlands International.

Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Goes, F., Hong Chamnan, Suon Mean, Luon Keng and Meas Rethy (1998) *Waterbird counting and survey at Prek Toal and Boeng Chhma/Moat Khla, May-June 1998.* Phnom Penh: Tonle Sap Technical Coordination Unit/Ministry of Environment.

Goes F. and Hong Chamnan (2002) *The status and conservation of large waterbirds on the Tonle Sap Great Lake, Cambodia 2000-2001.* Phnom Penh: Wildlife Conservation Society.

McDonald, A., Pech Bunnat, Phauk Virak and Leen Bunton (1997) *Plant communities of the Tonle Sap floodplain*. Phnom Penh: UNESCO.

Mundkur, T., Carr, P., Sun Hean and Chhim Somean (1995) *Surveys for large waterbirds in Cambodia, March-April 1994.* Cambridge, UK: IUCN/SSC.

Parr, J. W. K., Eames, J. C., Sun Hean, Hong Chammnan, Som Han, Vi La Pich and Seng Kim Hout (1996) *Biological and social aspects of waterbird exploitation and natural resource utilization of Prek Toal, Tonle Sap Lake, Cambodia.* Cambridge, UK: IUCN/SSC.